# Tips for Reading with your CHILDREN

**Cambodian**

---

# គន្លឹះសំរាប់អានសៀវភៅ
# ជាមួយកូនរបស់អ្នក

**1.** ***ចំណាយពេលជាមួយកូនអ្នក ដើម្បីជជែកលេង និទានរឿង និងច្រៀងចំរៀង ។***
ទាំងនេះជាសកម្មភាពដ៏រីករាយ ដែលអាចជួយកូនអ្នកក្នុងការរៀនអាន ។

**2.** ***អានឲ្យកូនស្តាប់ និងអានជាមួយកូនជារៀ ងរាល់ថ្ងៃ ។***
នេះបង្ហាញថា ការអាន និងចំណាយពេលជាមួយគ្នាជារៀងរាល់ថ្ងៃ គឺជាការសំខាន់ ។

**3.** ***ឲ្យកូនជួយជ្រើសរើសសៀវភៅដើម្បីអានជាមួយគ្នា ។***
វានឹងជួយធ្វើឲ្យកូនអ្នកចូលចិត្តអាន ។

**4.** ***រកកន្លែងស្រួលអង្គុយអាន ហើយត្រូវអង្គុយជិតកូន ។***
វាជួយបង្កើតអារម្មណ៍ល្អក្នុងពេលអាន ។

**5.** ***ផ្លាស់ប្តូរសំឡេង និងល្បឿនក្នុងការអានទៅតាមសាច់រឿង ។***
វាធ្វើឲ្យកុមារកាន់តែចង់ស្តាប់រឿង ។

**6.** ***បន្ទាប់ពីអានសៀវភៅមួយចប់ សូមពិភាក្សាអំពីសាច់រឿងជាមួយកូន ។***
ពិភាក្សាអំពីរូបភាព និងគំនិតចំបងក្នុងសៀវភៅ ជួយឲ្យមានការយល់ដឹងកាន់តែខ្លាំង ។

**7.** ***បង្ហាញឲ្យកូនឃើញអ្នកអានសៀវភៅ កាសែត និងទស្សនាវដ្តីនានា ។***
វាជាគំរូល្អសំរាប់កូន ពេលគេដឹងថា អ្នកចូលចិត្តការអាន នឹងឲ្យតំលៃខ្ពស់ដល់ការអាន ។

**8.** ***យកកូនទៅបណ្ណាល័យឲ្យបានទៀងទាត់ ។***
បណ្ណាល័យជាកន្លែងដ៏ល្អក្នុងការរកសៀវភៅអាន និងពត៌មានផ្សេងៗទៀតជាច្រើន ។

The minnesota humanities COMMISSION

For more information please contact:
Family Literacy Initiatives, 987 East Ivy Avenue, St. Paul, MN 55106
Ph) 651-772-4246 Fax) 651-774-0205 www.minnesotahumanities.org